ព្រះគម្ពីរសំរាប់កុមារ

សូមបង្ហាញជូន



# ណូអា
# និងទឹកជំនន់ធំ

និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus
Alastair Paterson

កែសម្រួលដោយ៖ M. Maillot; Tammy S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2020 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

ណូអាជាមនុស្សដែលគោរពបូជាព្រះ។ អ្នកគ្រប់គ្នាផ្សេងទៀតស្អប់ និងមិនស្តាប់បង្គាប់ព្រះ។




ថ្ងៃមួយ ព្រះជាម្ចាស់បាន
មានបន្ទូលពីរឿងមួយដ៏
គួរអោយរន្ធត់។ ព្រះ
ជាម្ចាស់ប្រាប់ណូអាថា
“យើងនឹង បំផ្លាញពិភព
លោកដ៏
អាក្រក់នេះ
មានតែគ្រួសារ
របស់ឯ
ងប៉ុណ្ណោះ ដែល
នឹងត្រូវ បានស
ង្គ្រោះ។”

ព្រះជាម្ចាស់បានព្រមានដល់ណូអាថា
ទឹកជំនន់ដ៏ធំមួយនឹងមកដល់ ហើយ
គ្របដណ្ដប់លើផែនដីនេះ។



ព្រះជា ម្ចាស់បានបញ្ជាណូអាអោយសង់
ទូកធ្វើពីសំបកឈើដ៏ធំមួយដែលអាច
ដាក់ គ្រួសាររបស់ណូអា និងសត្វជា
ច្រើន បាន។ ព្រះជាម្ចាស់បានផ្ដល់
ការណែនាំ យ៉ាងជាក់លាក់
ដល់ណូអា។ ណូអាបាន
ចាប់ផ្ដើម
ធ្វើការ។





ពេលដែលណូអា
ពន្យល់ដល់គ្រប់គ្នា
ពីមូលហេតុដែលគា
ត់សង់
ទូក មនុ

ស្សទាំងនោះ
បានសើច
ចំអកដល់ណូអា។



ណូ អា នៅបន្តសាងសង់ទូក ហើយគាត់ក៏នៅបន្តប្រាប់គ្រប់គ្នា

អំពីព្រះជាម្ចាស់ផងដែរ ប៉ុន្តែគ្មាននរណាម្នាក់ស្តាប់គាត់ឡើយ។


ណូអាមានជំនឿសប់លើព្រះជាម្ចាស់។ គាត់
បានជឿលើព្រះជាម្ចាស់ទោះបីជាភ្លៀង
មិនដែលធ្លាក់មកពី
មុនមកក៏ដោយ។


មិនយូរប៉ុន្មាន ទូកឈើបានរួចរាល់ដែល
អាចដាក់ផ្ទុកស្បៀងបាន។

ពេលនេះដល់វេនដាក់សត្វម្តង។ ព្រះជាម្ចាស់បាននាំសត្វ៧ពួកមក មួយគូរមួយពួក។



សត្វបក្សាបក្សីមានធំមានតូច,
សត្វព្រៃមានទាប មានខ្ពស់បានធ្វើដំណើរឡើង
ទៅលើទូក។





មនុស្សម្នាស្រែកសើចចំអកអោយណូអាពេល
ដែលគាត់អោយសត្វទាំងនោះឡើង ទូក។ ពួក
គេទាំងនោះមិនបាន បញ្ឈប់អំពើបាប
ប្រឆាំងនឹងព្រះ ជាម្ចាស់ឡើយ។
ពួកគេមិន បានសុំឡើងទូក
ជាមួយណូអាទេ។



នៅទីបំផុត
គ្រប់សត្វ
និងបក្សាបក្សីទាំងអស់បាន
ឡើងលើទូកអស់។



ព្រះជាម្ចាស់បាន
អញ្ជើញណូអា
“ចូលមកក្នុងទូក
មក អែងនិង
គ្រួសាររបស់អែង។”



ណូអា,
ប្រពន្ធរបស់គាត់,
កូនប្រុសបីនាក់របស់គាត់
និងប្រពន្ធរបស់ពួកគេបាន
ចូលក្នុងទូក។ ក្រោយមកព្រះ
ជាម្ចាស់បានបិទទ្វារ!



បន្ទាប់មកភ្លៀងបានចាប់ផ្តើមធ្លាក់។
ភ្លៀងធ្លាក់ជោគជាំយ៉ាងខ្លាំងរយៈ
ពេល៤០យប់ ៤០ថ្ងៃ។



ទឹកជំនន់
ជន់លិចអស់ទីក្រុង
និងភូមិនានា។ ពេលដែលមេឃ
ឈប់ភ្លៀង សូម្បីតែភ្នំក៏នៅក្រោមទឹកដែរ។



គ្រប់យ៉ាងដែលរស់បានដោយសារ
ខ្យល់ជាដង្ហើមបានស្លាប់អស់។



នៅពេលទឹកកើនឡើង
ទូកឈើបានអណ្តែតឡើង។
វ៉ាអាចនឹងងងឹត, រលាក់
ហើយប្រហែលជាគួរអោយ
ខ្លាចណាស់ ប៉ុន្តែទូកឈើ
នេះបានសង្គ្រោះណូអាពី
ទឹកជំនន់។

បន្ទាប់ពីទឹកជំនន់រយៈពេល៥ខែ
ព្រះជាម្ចាស់បានបញ្ជូនខ្យល់ស្ងួតម
ក។ មិនយូរប៉ុន្មាន ទូកឈើបាន
ឈប់នៅលើកំពូលភ្នំ អារ៉ារ៉ាត់។





ណូអាបន្តស្នាក់នៅក្នុងទូករយៈ
ពេល៤០ថ្ងៃបន្ថែមទៀ
តរហូតដល់ទឹក
ស្រកអស់។

ណូអាបានបញ្ជូនសត្វក្អែក និងសត្វព្រាប ចេញតាមបង្អួចទូក។ ដោយមិនអាចស្វែងរកទីស្អាតស្ងួតដើម្បីសំរាកបាន សត្វព្រាបបានត្រលប់មករកណូអាវិញ។



មួយសប្ដាហ៍ក្រោយមក,
ណូ អាបានព្យាយាមម្ដង
ទៀត។



សត្វព្រាបបានត្រលប់
មក វិញជាមួយស្លឹកអូ
លីវថ្មីមួយនៅក្នុងជំពូក
របស់វា។ នៅស ប្ដាហ៍បន្ទាប់
ណូអាបានដឹងថា ផែនដីបា
នស្ងួតហើយ ពីព្រោះ
ថាសត្វព្រាបមិនបាន
ត្រលប់មកវិញ។

ព្រះជាម្ចាស់បានប្រាប់ដល់ណូអាថា ដល់ពេល
ចេញពីទូកបានហើយ។ ណូអា
និងគ្រួសាររបស់គាត់បានរួមគ្នា
នាំសត្វទាំង
អស់ចេញពីទូក។




ណូអាពិតជាដឹ
ងគុណដល់ព្រះ
ជាម្ចាស់ខ្លាំងណាស់!

គាត់បានសាងសង់ថ្មើរគោរពបូជាមួយ
ហើយបានគោរព
បូជាព្រះ
ដែលបានសង្គ្រោះ
គាត់ និងគ្រួសា
ររបស់គាត់ពី
ទឹកជំនន់ដ៏សាហាវនេះ។





ព្រះជាម្ចាស់បាន
អោយការសន្យាដ៏អ
ស្ចារ្យមួយដល់ណូអា។

ទ្រង់ថាទ្រង់នឹងមិន
កាត់ក្តីអំពើបាបរបស់
មនុស្សដោយទឹក
ជំនន់ទៀត ឡើយ។



ព្រះទ្រង់បាន
អោយការ
រំលឹកដ៏អស្ចារ្យមួយនៃ
ពាក្យសន្យារបស់ទ្រង់។

ឥន្ធនូគឺជាសញ្ញានៃ
ការសន្យារបស់ទ្រង់។

ណូអា និងគ្រួសារ
របស់គាត់បានចាប់
ផ្តើមជីវិតថ្មីបន្ទាប់ពីទឹក
ជំនន់។



យូរទៅ កូនចៅរបស់គាត់បាន
បំពេញមនុស្សលើផែនដីនេះ។
គ្រប់ជាតិសាសន៍នៅលើ
លោកនេះមានកំណើត
មកពីណូអា
និងកូនៗរបស់គាត់។



# ណូអា និងទឹកជំនន់ធំ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់,
ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

លោកុប្បត្តិ ៦-១០

“ការបើកសម្តែងនូវព្រះបន្ទូលទ្រង់ផ្តល់នូវពន្លឺ។” ទំនុកតម្កើង ១១៩៖ ១៣០


ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់ យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្លេះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់
ព្រះអង្គថា៖ ឱព្រះយេស៊ូ ទូលបង្គំជឿហើយថាទ្រង់ជាព្រះ
ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួស
អំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគត
ឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ
ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បី
ទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃ
មួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូម
ជួយទូលបង្គំអោយគោរពទ្រង់ ហើយរស់នៅសំរាប់ទ្រង់
ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!
យ៉ូហាន ៣៖១៦